សន្លឹកព័ត៌មានស្តីពីថ្នាំវ៉ាក់សាំង

# ថ្នាំវ៉ាក់សាំង DTaP

## *អ្វីដែលអ្នកត្រូវដឹង*

(ជំងឺខាន់ស្លាក់ តេតាណូស ក្អកមាន់)

Many Vaccine Information Statements are available in Khmer and other languages. See www.immunize.org/vis

សន្លឹកព័ត៌មានស្តីពីថ្នាំវ៉ាក់សាំងជាច្រើនមានជាភាសាខ្មែរ និងភាសាផ្សេងទៀត។ សូមចូលទៅ www.immunize.org/vis

## 1 ហេតុអ្វីត្រូវទទួលថ្នាំបង្ការ?

**ជំងឺខាន់ស្លាក់ តេតាណូស និងក្អកមាន់គឺជាជំងឺធ្ងន់ធ្ងរដែលបង្កឡើងដោយបាក់តេរី។** ជំងឺខាន់ស្លាក់ និងក្អកមាន់ចម្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត។ តេតាណូសឆ្លងចូលខ្លួនប្រាណតាមរយៈស្នាមមុត ឬរបួស។

**ជំងឺខាន់ស្លាក់** បណ្តាលឲ្យឡើងស្លេសនៅបំពង់ក។

- ជំងឺនេះបណ្តាលឲ្យមានបញ្ហាដកដង្ហើម រោគខ្វិន រោគចុះខ្សោយបេះដូង និងស្លាប់បាត់បង់ជីវិត។

**តេតាណូស (ជំងឺរឹងថ្គាម)** ធ្វើឲ្យតឹងសាច់ដុំជាមួយនឹងការឈឺចុកចាប់ ដែលជាធម្មតា ពេញខ្លួនប្រាណទាំងមូល។

- តេតាណូសអាចបណ្តាលឲ្យ"រឹង"ថ្គាម ដូច្នេះជនរងគ្រោះមិនអាចហាមាត់ ឬលេបបានឡើយ។ តេតាណូសអាចបណ្តាលឲ្យស្លាប់បាត់បង់ជីវិត 2 ករណីក្នុងចំណោម 10 ករណី។

**ជំងឺក្អកមាន់ (ក្អកមួបៗ)** បណ្តាលឲ្យក្អកយូរខ្លាំងដែលធ្វើឲ្យកុមារពិបាកញ៉ាំ ផឹក ឬដកដង្ហើម។ ការក្អកយូរនេះអាចមានរយៈពេលច្រើនសប្តាហ៍។

- ជំងឺនេះអាចបណ្តាលឲ្យកើតជំងឺរលាកសួត ប្រកាច់ (កន្ត្រាក់ និងឈរភ្នែក) ខូចខួរក្បាល និងស្លាប់បាត់បង់ជីវិត។

**ថ្នាំវ៉ាក់សាំងជំងឺខាន់ស្លាក់ តេតាណូស និងក្អកមាន់ (DTaP) អាចជួយបង្ការជំងឺទាំងនេះបាន។** កុមារភាគច្រើន ដែលបានទទួលថ្នាំវ៉ាក់សាំង DTaP នឹងទទួលបានការការពារក្នុងអំឡុងកុមារភាពទាំងមូល។ កុមារជាច្រើនថែមទៀតនឹងកើតជំងឺទាំងនេះ ប្រសិនបើយើងឈប់ផ្តល់ថ្នាំវ៉ាក់សាំង។

ថ្នាំវ៉ាក់សាំង DTaP គឺជាថ្នាំដែលមានសុវត្ថិភាពជាងថ្នាំវ៉ាក់សាំងមុនដែលគេហៅថាថ្នាំវ៉ាក់សាំង DTP។ ថ្នាំវ៉ាក់សាំង DTP លែងត្រូវបានគេយកមកប្រើប្រាស់ក្នុងសហរដ្ឋអាមេរិកតទៅទៀតហើយ។

## 2 តើអ្នកណាគួរទទួលថ្នាំវ៉ាក់សាំង DTaP ហើយនៅពេលណា?

**កុមារ** គួរទទួលថ្នាំវ៉ាក់សាំង DTaP ចំនួន 5 ដូស ដោយថ្នាំវ៉ាក់សាំងមួយដូសៗ ត្រូវចាក់នៅអាយុដូចតទៅ ៖

- 2 ខែ
- 4 ខែ
- 6 ខែ
- 15–18 ខែ
- 4–6 ឆ្នាំ

ថ្នាំវ៉ាក់សាំង DTaP អាចផ្តល់ជូន ក្នុងពេលជំណាលគ្នានឹងថ្នាំវ៉ាក់សាំងដទៃទៀត។

## 3 កុមារមួយចំនួនមិនគួរទទួលថ្នាំវ៉ាក់សាំង DTaP ទេ ឬគួររង់ចាំ

- កុមារដែលមានជំងឺស្រាល ដូចជាជំងឺផ្តាសាយ អាចទទួលថ្នាំបង្ការនេះបាន។ ប៉ុន្តែជាធម្មតា កុមារដែលមានជំងឺធ្ងន់ល្មម ឬធ្ងន់ធ្ងរ គួររង់ចាំ រហូតដល់ពួកគេជាសះស្បើយសិន មុនពេលទទួលថ្នាំវ៉ាក់សាំង DTaP។
- កុមារ ដែលមានប្រតិកម្មអាឡាក់ស៊ីដែលគំរាមដល់អាយុជីវិត បន្ទាប់ពីទទួលថ្នាំវ៉ាក់សាំង DTaP មួយដូសនោះ មិនគួរទទួលថ្នាំបង្ការនេះមួយដូសទៀតទេ។
- កុមារ ដែលមានជំងឺប្រព័ន្ធប្រសាទ ឬខួរក្បាលក្នុងរយៈពេល 7 ថ្ងៃបន្ទាប់ពីទទួលថ្នាំវ៉ាក់សាំង DTaP មួយដូសនោះ មិនគួរទទួលថ្នាំបង្ការនេះមួយដូសទៀតទេ។
- សូមពិភាក្សាជាមួយនឹងវេជ្ជបណ្ឌិតរបស់លោកអ្នក ប្រសិនបើកូនរបស់លោកអ្នក ៖
  - ប្រកាច់ ឬដួលបន្ទាប់ពីទទួលថ្នាំបង្ការ DTaP មួយដូស
  - ស្រែកយំមិនឈប់រយៈពេល 3 ម៉ោង ឬលើសពីនេះ បន្ទាប់ពីទទួលថ្នាំបង្ការ DTaP មួយដូស
  - មានជំងឺគ្រុនក្តៅលើស 105°F បន្ទាប់ពីទទួលថ្នាំបង្ការ DTaP មួយដូស។

សូមសួរវេជ្ជបណ្ឌិតរបស់លោកអ្នកសម្រាប់ព័ត៌មានបន្ថែមទៀត។ កុមារទាំងនេះមួយចំនួនមិនគួរទទួលថ្នាំវ៉ាក់សាំងជំងឺក្អកមាន់មួយដូសទៀតឡើយ ប៉ុន្តែអាចទទួលថ្នាំវ៉ាក់សាំងដែលគ្មានថ្នាំវ៉ាក់សាំងជំងឺក្អកមាន់បាន ដែលគេហៅថា **ថ្នាំវ៉ាក់សាំង DT**។

## 4 កុមារអាយុច្រើន និងមនុស្សពេញវ័យ

ថ្នាំវ៉ាក់សាំង DTaP ពុំត្រូវបានចេញអាជ្ញាប័ណ្ណសម្រាប់យុវជន មនុស្សពេញវ័យ ឬកុមារអាយុ 7 ឆ្នាំ និងលើសពី 7 ឆ្នាំឡើយ។

ប៉ុន្តែមនុស្សវ័យកាន់តែច្រើននៅតែត្រូវការកិច្ចការពារ។ ថ្នាំវ៉ាក់សាំងមួយដែលគេហៅថា **ថ្នាំវ៉ាក់សាំង Tdap** មានលក្ខណៈប្រហាក់ប្រហែលនឹងថ្នាំវ៉ាក់សាំង DTaP ដែរ។ ថ្នាំវ៉ាក់សាំង Tdap តែមួយដូសត្រូវបានណែនាំសម្រាប់មនុស្សអាយុពី 11 ឆ្នាំដល់ 64 ឆ្នាំ។ ថ្នាំវ៉ាក់សាំងមួយទៀត ដែលគេហៅថា **ថ្នាំវ៉ាក់សាំង Td** ការពារចំពោះតេតាណូស និងជំងឺខាន់ស្លាក់ ប៉ុន្តែមិនការពារចំពោះជំងឺក្អកមាន់ទេ។ គេណែនាំឲ្យទទួលថ្នាំវ៉ាក់សាំងនេះរៀងរាល់ 10 ឆ្នាំម្តង។ មានសន្លឹកព័ត៌មានស្តីពីថ្នាំវ៉ាក់សាំង (Vaccine Information Statement) ដោយឡែកសម្រាប់ថ្នាំវ៉ាក់សាំងទាំងនេះ។



U.S. Department of Health and Human Services
Centers for Disease Control and Prevention

## 5 តើមានហានិភ័យអ្វីខ្លះដោយសារថ្នាំវ៉ាក់សាំង DTaP?

ការកើតជំងឺខាន់ស្លាក់ តេតាណូស ឬក្អកមាន់មានហានិភ័យខ្ពស់ជាងការទទួលថ្នាំវ៉ាក់សាំង DTaP។

ទោះជាយ៉ាងណា ថ្នាំវ៉ាក់សាំង គឺដូចឱសថផងដែរ គឺអាចបង្កបញ្ហាធ្ងន់ធ្ងរ ដូចជាប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ។ ហានិភ័យដែលថ្នាំវ៉ាក់សាំង DTaP បង្កគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬធ្វើឲ្យស្លាប់បាត់បង់ជីវិតនោះ គឺមានកម្រិតតិចបំផុត។

**បញ្ហាស្រាល (ធម្មតា)**

- គ្រុនក្តៅ (កុមារប្រហែលម្នាក់ក្នុងចំណោម 4 នាក់)
- ស្នាមក្រហម ឬហើមត្រង់កន្លែងចាក់ថ្នាំ (កុមារប្រហែលម្នាក់ក្នុងចំណោម 4 នាក់)
- ដំបៅ ឬឆាប់ឈឺត្រង់កន្លែងចាក់ថ្នាំ (កុមារប្រហែលម្នាក់ក្នុងចំណោម 4 នាក់)

បញ្ហាទាំងនេះកើតឡើងកាន់តែញឹកញាប់ថែមទៀតបន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំង DTaP ដូសទី 4 និងទី 5 គឺញឹកញាប់ជាងថ្នាំវ៉ាក់សាំងដូសមុនៗ។ ជួនកាល បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំង DTaP ដូសទី 4 ឬទី 5 រួច ដៃ ឬជើងទាំងមូល ដែលចាក់ថ្នាំនោះ ឡើងហើមរយៈពេលពី 1–7 ថ្ងៃ (កុមារប្រហែលម្នាក់ក្នុងចំណោម 30 នាក់)។

**បញ្ហាស្រាលដទៃទៀតរួមបញ្ចូល ៖**

- មួរម៉ៅ (កុមារប្រហែលម្នាក់ក្នុងចំណោម 3 នាក់)
- នឿយហត់ ឬមិនសូវមានចំណង់អាហារ (កុមារប្រហែលម្នាក់ក្នុងចំណោម 10 នាក់)
- ក្អួត (កុមារប្រហែលម្នាក់ក្នុងចំណោម 50 នាក់)

ជាទូទៅ បញ្ហាទាំងនេះកើតឡើងរយៈពេល 1–3 ថ្ងៃបន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំង។

**បញ្ហាធ្ងន់ល្មម (មិនធម្មតា)**

- ប្រកាច់ (កន្ត្រាក់ ឬឈរភ្នែក) (កុមារប្រហែលម្នាក់ក្នុងចំណោម 14,000 នាក់)
- ស្រែកយំមិនឈប់រយៈពេល 3 ម៉ោង ឬលើសពី 3 ម៉ោង (កុមារប្រហែលម្នាក់ក្នុងចំណោម 1,000 នាក់)
- គន្រក្តៅខ្លាំងលើសពី 105°F (កុមារប្រហែលម្នាក់ក្នុងចំណោម 16,000 នាក់)

**បញ្ហាធ្ងន់ធ្ងរ (កម្រណាស់)**

- ប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ (តិចជាងម្តងក្នុងចំណោមមួយលានដូស)
- បញ្ហាធ្ងន់ធ្ងរដទៃទៀតជាច្រើនត្រូវបានរាយការណ៍ថាកើតមាន បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំង DTaP។ បញ្ហាទាំងនេះរួមបញ្ចូល៖
  - ប្រកាច់យូរ សន្លប់បាត់ស្មារតី ឬស្មារតីថយចុះ
  - ខូចខួរក្បាលជាអចិន្ត្រៃយ៍

  បញ្ហាទាំងនេះគឺកម្រណាស់ ដូច្នេះគេពិបាកនិយាយថាតើ បញ្ហាទាំងនេះបង្កឡើងដោយថ្នាំវ៉ាក់សាំង ឬយ៉ាងណាទេ។

---

ការគ្រប់គ្រងគ្រុនក្តៅមានសារៈសំខាន់ជាពិសេសចំពោះកុមារដែលធ្លាប់ប្រកាច់។ ការគ្រប់គ្រងគ្រុនក្តៅក៏ជាការសំខាន់ផងដែរ ប្រសិនបើសមាជិកម្នាក់ទៀតក្នុងគ្រួសារធ្លាប់ប្រកាច់។ អ្នកអាចកាត់បន្ថយគ្រុនក្តៅ និងការឈឺចុកចាប់ ដោយឲ្យថ្នាំបន្ថយការឈឺចុកចាប់*ដែលគ្មានថ្នាំ aspirin* ដល់កូនអ្នក នៅពេលចាក់ថ្នាំវ៉ាក់សាំង និងរយៈពេល 24 ម៉ោងបន្ទាប់ អនុលោមតាមសេចក្តីណែនាំក្នុងកញ្ចប់ថ្នាំវ៉ាក់សាំង។

DCH-0469CA AUTH: P. H. S., Act 42, Sect. 2126.
Translation provided by the Immunization Action Coalition

## 6 ចុះបើមានប្រតិកម្មធ្ងន់ធ្ងរ?

**តើខ្ញុំគួរប្រយ័ត្នចំពោះអ្វីខ្លះ?**

- សូមប្រយ័ត្នចំពោះអ្វីដែលធ្វើឲ្យលោកអ្នកព្រួយបារម្ភ ដូចជាសញ្ញាបង្ហាញពីប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ គ្រុនក្តៅខ្លាំង ឬការប្តូរឥរិយាបថ។

  សញ្ញាបង្ហាញពីប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ អាចរួមបញ្ចូលកន្ទួល ហើមមុខនិងបំពង់ក ពិបាកដកដង្ហើម ចង្វាក់បេះដូងញាប់ វិលមុខ និងកម្លាំងចុះខ្សោយ។ បញ្ហាទាំងនេះនឹងចាប់ផ្តើមកើតឡើងប៉ុន្មាននាទីទៅប៉ុន្មានម៉ោងប៉ុណ្ណោះបន្ទាប់ពីការចាក់ថ្នាំបង្ការ។

**តើខ្ញុំគួរធ្វើអ្វីខ្លះ?**

- ប្រសិនបើលោកអ្នកគិតថា វាគឺជាប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ ឬស្ថានការណ៍សង្គ្រោះបន្ទាន់ដទៃទៀតដែលមិនអាចរង់ចាំបាន សូមទូរស័ព្ទទៅ 9-1-1 ឬយកអ្នកជំងឺទៅកាន់មន្ទីរពេទ្យដែលជិតបំផុត។ បើមិនអញ្ចឹងទេ សូមទូរស័ព្ទទៅវេជ្ជបណ្ឌិតរបស់លោកអ្នក។
- បន្ទាប់មក ប្រតិកម្មគួររាយការណ៍ទៅប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំវ៉ាក់សាំង (Vaccine Adverse Event Reporting System (VAERS))។ វេជ្ជបណ្ឌិតរបស់លោកអ្នកអាចដាក់បញ្ជូនរបាយការណ៍នេះ ឬលោកអ្នកអាចរាយការណ៍ដោយផ្ទាល់តាមរយៈវេបសាយ VAERS នៅ **www.vaers.hhs.gov** ឬតាមរយៈហៅទូរស័ព្ទមក **1-800-822-7967**។

*VAERS គឺសម្រាប់តែការរាយការណ៍ប្រតិកម្មផ្សេងៗប៉ុណ្ណោះ។ ប្រព័ន្ធនេះពុំផ្តល់ដំបូន្មានវេជ្ជសាស្ត្រទេ។*

## 7 កម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង (National Vaccine Injury Compensation Program)

កម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង (National Vaccine Injury Compensation Program (VICP)) គឺជាកម្មវិធីរបស់រដ្ឋសហព័ន្ធដែលបានបង្កើតឡើងដើម្បីបង់សងអ្នកទាំងឡាយដែលអាចរងរបួសដោយសារតែថ្នាំវ៉ាក់សាំងមួយចំនួន។

បុគ្គលដែលជឿជាក់ថា ខ្លួនអាចធ្លាប់រងរបួសដោយសារថ្នាំវ៉ាក់សាំងមួយអាចធ្វើការសិក្សាអំពីកម្មវិធី និងអំពីការដាក់ពាក្យទាមទារសំណង ដោយទូរស័ព្ទមក**1-800-338-2382** ឬចូលទៅវេបសាយ VICP នៅ **www.hrsa.gov/vaccinecompensation**។

## 8 តើខ្ញុំអាចសិក្សាបន្ថែមទៀតដោយរបៀបណា?

- សួរវេជ្ជបណ្ឌិតរបស់លោកអ្នក។ 1-888-767-4687
- ទូរស័ព្ទទៅក្រសួងសុខាភិបាលរដ្ឋ ឬនៅមូលដ្ឋានរបស់លោកអ្នក។
- ទាក់ទងមជ្ឈមណ្ឌលទប់ស្កាត់ និងបង្ការជំងឺឆ្លង (CDC):
  - ទូរស័ព្ទមកលេខ **1-800-232-4636 (1-800-CDC-INFO)** ឬ
  - ចូលទៅវេបសាយ CDC នៅ **www.cdc.gov/vaccines**

---

Vaccine Information Statement

# DTaP Vaccine

5/17/2007 Khmer

42 U.S.C. § 300aa-26

Office Use Only

ដើម្បីអនុញ្ញាតឲ្យអ្នកផ្តល់ការព្យាបាលសុខភាពស្នើសុំនូវពត៌មានអំពីការចាក់ថ្នាំបង្ការរោគពេញលក្ខណគ្រឹមត្រូវ, ការពិនិត្យមើលនៃការចាក់ថ្នាំបង្ការរោគ ហើយនិងការតម្រូវដាក់ពេលវេលា សំរាប់ចាក់ថ្នាំបង្ការរោគនៅអនាគត, ពត៌មានអំពីការចាក់បង្ការរោគនឹងផ្ញើទៅមន្ទីរ Michigan Care Improvement Registry ។ បុគ្គលទាំងឡាយមានសិទ្ធិស្នើសុំអោយអ្នកផ្តល់ការព្យាបាលសុខ ភាពមិនអោយបញ្ជូនពត៌មានអំពីការចាក់ថ្នាំបង្ការរោគនេះទៅឲ្យកន្លែងទុកសំណុំរឿងបាន។